ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៥០

ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៧

<u>សាលដីកា</u>

លេខ : ២៨

ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

១- ឯកឧត្តម [redacted] ប្រធាន

២- លោក [redacted] ចៅក្រម

៣- លោក [redacted] ចៅក្រម

៤- លោក [redacted] ចៅក្រមរបាយការណ៍

៥- លោក [redacted] ចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០២ "ច" ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៥០ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៧របស់តុលាការកំពូល ។

<u>**ពីបទ**</u> : សម្លាប់មនុស្សដោយចេតនា ប្រព្រឹត្តនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ជៀច ខេត្តព្រៃវែង កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោស នៃបទឧក្រិដ្ឋ ។

១-ជនជាប់ចោទឈ្មោះ [redacted] ម៉ាត់ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនិងទីលំនៅសព្វថ្ងៃ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន៤នាក់ ។ ទោសពីមុនគ្មាន ។ ក្រៅឃុំ ។

- មានមេធាវីលោក [redacted] ម៉ារ៉ះ

២-ជនជាប់ចោទឈ្មោះ [redacted] ទាង ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនិងទីលំនៅសព្វថ្ងៃ [redacted] ខេត្តព្រៃវែង ទោសពីមុនគ្មាន ។ គេចខ្លួន ។

Scanned with CamScanner

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិកណ្តាច់ ឃុំចុងអំពិល ស្រុកកញ្ជៀច ខេត្តព្រៃវែង ។

- លោកស្រីមេធាវី [redacted] **សុវ៉ន**

តាមពាក្យបណ្តឹងចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះ [redacted] ប្តឹងពីឈ្មោះ [redacted] ម៉ាត់ . [redacted] នាង . [redacted] ចេន ពីបទ : សម្លាប់កូនបង្កើតរបស់ខ្លួនឈ្មោះ [redacted] សុភា ដោយសំអាងហេតុថា មុនថ្ងៃកើតហេតុជាប់៧ថ្ងៃ ឈ្មោះ [redacted] នាង បានបបួលកូនរបស់ខ្លួនជាច្រើនលើក តែកូនរបស់ខ្លួនមិនព្រមទៅ ។ លុះដល់ថ្ងៃកើតហេតុថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ វេលាម៉ោង៧យប់ បានបបួលហើយនាំគ្នាទៅផ្ទះឈ្មោះ [redacted] ម៉ាត់ កូនរបស់ខ្លួនឃើញឈ្មោះហូវ នៅលើផ្ទះឈ្មោះ [redacted] ម៉ាត់ ក៏នាំគ្នាមកផ្ទះវិញ ព្រោះឈ្មោះហូវ ធ្លាប់មានទំនាស់គ្នាកន្លងមក ។ ដល់ម៉ោង១២យប់ថ្ងៃដដែលឈ្មោះ [redacted] នាង មកបបួលកូនរបស់ខ្លួនម្តងទៀត ។ នៅលើផ្ទះ [redacted] ម៉ាត់ មិនឃើញឈ្មោះហូវ នៅលើផ្ទះ [redacted] ម៉ាត់ ទេ កូនខ្លួនទាំងពីរក៏នៅផឹក ដោយមានគ្នា៨នាក់ គឺប្រុស៥នាក់ ស្រី៣នាក់ មានឈ្មោះ [redacted] នាង . [redacted] ចេន . [redacted] ភ៊ាឌី . [redacted] សុភា . [redacted] វី . [redacted] ម៉ៅ [redacted] ស្រី . [redacted] ឆេង និង [redacted] ម៉ាត់ ពេលផឹកដល់ម៉ោង២យប់ ប្អូនបានបបួលមកផ្ទះតែឈ្មោះខាងលើមិនឱ្យឈ្មោះ [redacted] សុភា (ជនរងគ្រោះ) មក ទេគឺសុខចិត្តឱ្យឈ្មោះ [redacted] នាង បើករថយន្តជូនប្អូនឈ្មោះ ហ៊ី ភ៊ាឌី មកផ្ទះ ។ លុះដល់ម៉ោង៣.៣០នាទី មានដំណឹងថាកូនរបស់ខ្លួនឈ្មោះ [redacted] សុភា ស្លាប់ ។ ខ្លួនទៅដល់ឃើញកូនដេកស្លាប់មានស្នាមបែកក្បាលនិងស្នាមជាំជាច្រើន ត្រង់ក និងដងខ្លួន ដែលមិនអាចជារឿងគ្រោះថ្នាក់ចរាចរ ។ សំណូមពរសុំស្រាវជ្រាវរកជនល្មើស អ្នកដៃដល់ អ្នកសមគំនិត ផ្តន្ទាទោសតាមច្បាប់ និងទាមទារជំងឺចិត្ត៥០លានរៀល ព្រមទាំងជួយរកយុត្តិធម៌ ។

-បានឃើញដីកាលើកលែងចោទប្រកាន់លេខ១៣១៩ ដលច០០២/០៥ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ របស់ចៅក្រមស៊ើបអង្កេតខេត្តព្រៃវែង ដែលបានសំរេច : លើកលែងចោទប្រកាន់លើឈ្មោះ [redacted] ម៉ាត់ ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ របរកសិ ធ្វើស្រែ ទីលំនៅកំណើត និងមុនពេលឃុំខ្លួននៅ [redacted] ខេត្តព្រៃវែង ឪពុក ឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូន៤នាក់ ទោសពីមុនគ្មានដែល ជាប់ចោទពីបទ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ជៀច ខេត្តព្រៃវែង កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៣ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] ដល. មិនសុខចិត្តពី ដីកាលើកលែងចោទប្រកាន់លេខ១៣១៩ ដលច០០២/០៥ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ របស់ ចៅក្រមស៊ើបអង្កេតខេត្តព្រៃវែង ត្រង់ចំណុចនៃដីកាទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] ដល ទុកជាត្រឹមត្រូវតាមគតិច្បាប់ ។

២-សុំបង្វិលសំណុំរឿងទៅតុលាការខេត្តព្រៃវែង ដើម្បីចាត់ការតាមនីតិវិធី ។



Scanned with CamScanner

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០២"ច" ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] ផល ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-បដិសេធដីកាលើកលែងចោទប្រកាន់លេខ១៣១៩ ដលច០០២/០៥ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៥ របស់ចៅក្រមស៊ើបអង្កេត តុលាការខេត្តព្រៃវែងចោលជាអសារបង់ ។

៣-ចោទប្រកាន់លើឈ្មោះ [redacted] ម៉ាត់ ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ.អ៊ិស្លាម ទីលំនៅ [redacted] ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង កាលពីថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ២០០៤ តាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទំងន់ទោស នៃបទឧក្រិដ្ឋ ។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៥៤៥ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ទៅ តុលាការខេត្តព្រៃវែង ដើម្បីចាត់ការតាមនីតិវិធី ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ដើមបណ្តឹង និងមេធាវីការពារដើមបណ្តឹង បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ២០៤ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ម៉ាត់ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ០២"ច" ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ម៉ាត់ "ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

-បានឃើញសារណាឆ្លើយតប ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ផល "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

+សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះត្រឹមត្រូវហើយ ។

+តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០២"ច" ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់ក្រឡាបញ្ជីអានសារណារបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ាត់ ។

-បានស្តាប់ចំលើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ឈ្មោះ [redacted] ម៉ាត់ និងឈ្មោះ [redacted] នាង បានមកបបួលកូនខ្លួនឈ្មោះ [redacted] ភា ទៅផឹកស៊ីជាមួយគ្នា ពេលទៅផឹកនោះខ្លួនមិនដឹងទេ ព្រោះខ្លួនដេកលក់ហើយ តែខ្លួនមានសាក្សីបំភ្លឺនៅតុលាការរួចហើយ ។ ឈ្មោះហូវ នៅផ្ទះ [redacted] ម៉ាត់ ជនរងគ្រោះឃើញឈ្មោះ ហូវ ទៅផ្ទះគេបាត់ ក៏ជនរងគ្រោះកូនខ្លួន



Scanned with CamScanner

3

ទៅផឹកទៅផ្ទះ [redacted] ម៉ាត់ ម្តងទៀត ។ ពីមុនមកឈ្មោះ [redacted] ចេន និងឈ្មោះ [redacted] នាង មិនដែលត្រូវគ្នាជាមួយខ្លួនទេ ព្រោះមានមុខរបរដូចគ្នា ។ ទ្វារបងផ្ទះមានប្រវែង២.១ម ចំណែកឡានមានទទឹងប្រវែង២.២ម មិនអាចចូលទៅបុកកូនខ្លួននៅជាប់មុខជណ្តើរផ្ទះរបស់ឈ្មោះ [redacted] ម៉ាត់ ទេ ។

សំណូមពរ : សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ និងបង្វិលសំណុំរឿងទៅតុលាការខេត្ត ចាត់ការតាមផ្លូវច្បាប់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] វាវៈ ការពារឱ្យជនជាប់ចោទ នៅពេលជំនុំជំរះថា: បើសិនជាឈ្មោះ [redacted] ម៉ាត់ បានហៅឈ្មោះ [redacted] ភា មកសំលាប់នៅក្នុងផ្ទះនោះ ជាការមិនត្រឹមត្រូវទេ ពីព្រោះថា ករណីនេះអាចបណ្តាលមកពីជនរងគ្រោះអាចស្ថិតក្នុងភាពស្រវឹងខ្លាំង ហើយរអិលដួល ហើយក៏ត្រូវរថយន្តកិន មិនមែនឡានបើកទៅបុកជនរងគ្រោះនេះទេ ។

សំណូមពរ : សុំឱ្យក្រុមប្រឹក្សាជំនុំជំរះសំរេចបដិសេធសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ និង សុំទាមទារសំណងជំងឺចិត្តឱ្យកូនក្តីខ្លួនចំនួន៣.០០០ដុល្លាអាមេរិក ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] សុវ៉ន មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី នៅពេលជំនុំជំរះថា :

+ការសំរេចលើកលែងការចោទប្រកាន់លេខ១៣១៩ ដ.ល.០០២/០៥ របស់លោកចៅក្រមស៊ើបអង្កេតតុលាការខេត្តព្រៃវែងលើឈ្មោះ លី ម៉ាត់ ពីបទ មនុស្សឃាតដោយចេតនា នោះពុំមានមូលហេតុត្រឹមត្រូវ និងសមហេតុសមផលនោះឡើយ ។

+ការសំរេចកែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] នាង ពីបទមនុស្សឃាតដោយចេតនា មកជាបទគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នោះពុំមានមូលដ្ឋានត្រឹមត្រូវឡើយ ។

+រឿងក្តីនេះជារឿងក្តីមនុស្សឃាតដោយចេតនាគិតទុកជាមុន ដោយជនល្មើសមានគូកន មានឈ្មោះ [redacted] ម៉ាត់ ភេទប្រុស អាយុ៤៣ឆ្នាំ [redacted] ចេន , [redacted] នាង មិនមែនជារឿងគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកទេ ។

សំណូមពរ ដល់លោកចៅក្រមប្រឹក្សា ក៏ដូចជាលោកតំណាងអយ្យការ សូមលោកពិនិត្យ និងប្តូរបទចោទទៅលើជនល្មើសឈ្មោះ [redacted] នាង ពីបទគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក មកជាបទមនុស្សឃាតដោយចេតនាគិតទុកជាមុន ហើយសុំឱ្យចោទឡើងវិញលើឈ្មោះ [redacted] ម៉ាត់ [redacted] ចេន ពីបទ មនុស្សឃាតដោយចេតនាគិតទុកជាមុន ដោយមានភស្តុតាងគ្រប់គ្រាន់លើសវិមតិសង្ស័យ អាចចោទប្រកាន់បាន និងដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះដែលស្លាប់ ។

សុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : ពុំមានយោបល់អ្វីបន្ថែមទៀតទេ .

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍



Scanned with CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២០៤ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ម៉ាត់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា៦០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលឈ្មោះ [redacted] ម៉ាត់ បានលើកឡើងក្នុងសារណាការពារខ្លួន ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ នោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា : ករណីដែលជនរងគ្រោះឈ្មោះ [redacted] សុភា ស្លាប់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ វេលាម៉ោង៣.៣០ភ្លឺ នៅក្នុងបរិវេណផ្ទះ [redacted] ម៉ាត់ នៅភូមិមានជ័យ ឃុំចុងអំពិល ស្រុកកញ្ច្រៀច ខេត្តព្រៃវែង នោះមានអង្គហេតុ ២ផ្ទុយគ្នា ដែលតុលាការខេត្តព្រៃវែង ពុំទាន់បានស្រាវជ្រាវស៊ើបអង្កេតនៅឡើយ គឺ :

**អង្គហេតុទី ១** : អំពីការស្លាប់របស់ឈ្មោះ [redacted] សុភា ដោយសារឈ្មោះ [redacted] នាង បើករថយន្តតូរ៉េ ទំងន់៥តោនបុកឈ្មោះ [redacted] សុភា ដែលឈរចាំឈ្មោះ [redacted] នាង បើករថយន្តនេះត្រឡប់មកពីជូនប្អូន [redacted] សុភា ទៅផ្ទះ ។ ស្លាកស្នាមរបួសដែល [redacted] សុភា មាននៅពេលនោះ វាពុំស៊ីសង្វាក់គ្នាទៅនឹងរបួសស្នាមដែលត្រូវមាននៅពេលរថយន្តបុកទេ ។

**អង្គហេតុទី២** : មានសាក្សីម្នាក់ឈ្មោះ [redacted] ផល បានឃើញផ្ទាល់ភ្នែកនៅយប់នោះតាមពន្លឺភ្លើងរថយន្តដែលបានបើកចូលផ្ទះ [redacted] ម៉ាត់ ឃើញ [redacted] ម៉ាត់ វាយ [redacted] សុភា នឹងព្រនង់ឈើ ឬដែក វាយចំខ្លួនត្រូវឆ្អឹងជំនីរ [redacted] សុភា រួចឃើញមនុស្ស២នាក់ទៀតចុះពីលើផ្ទះមកទៀត បន្ទាប់មកភ្លើងរថយន្តត្រូវបានបិទ ។

-យល់ឃើញថា មានសញ្ញាណផ្សេងទៀតដែលបញ្ជាក់ថា មរណភាពរបស់ជនរងគ្រោះពុំអាចបណ្តាលមកពីគ្រោះថ្នាក់ចរាចរបានទេ ពីព្រោះពេលដែលរថយន្តបត់ចូលផ្ទះជាធម្មតារថយន្តពុំអាចមានល្បឿន ដែលពុំអាចគ្រប់គ្រងបាន ហើយអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរបានទេ ដែលតម្រូវអោយធ្វើការស៊ើបអង្កេតអោយបានច្បាស់លាស់ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទសន្និដ្ឋានថា ករណីនេះអាចបណ្តាលមកពីជនរងគ្រោះអាចស្ថិតក្នុងភាពស្រវឹងខ្លាំង ហើយរអិលដួលហើយក៏ត្រូវរថយន្តកិននោះ ពុំមានសំអាងដែលអាចអោយតុលាការពិចារណាបានទេ ។



Scanned with CamScanner

89/1

-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ម៉ាត់ បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខឈ្មោះនេះ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០២"ច" ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ :**

១-ទទួលបណ្តឹងសាទុក្ខលេខ០៤ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ម៉ាត់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០២"ច" ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៧ របស់សាលា-ឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤០ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៧ របស់តុលាការកំពូលទៅតុលាការខេត្តព្រៃវែង ដើម្បីអនុវត្តតាមនីតិវិធី ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៨ ។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០០៨

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០០៨

ជ. ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]

Scanned with CamScanner